00916364

E288

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 05 / 06 / 2013
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣

**ជូនចំពោះ÷** ភាគីនៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** **ការជូនដំណឹងអំពីសវនាការដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយសម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣**

១ បន្ទាប់ពីមានការបំបែកជាថ្មីនៃកិច្ចដំណើរការនីតិវិធីសវនាការសំណុំរឿង០០២ និងចំណាត់ការលើសំណើយ៉ាងច្រើនសន្ធឹកសន្ធាប់ដែលភាគី បានដាក់នៅក្នុងអំឡុងពេលសវនាការ កន្លងមកអង្គជំនុំជម្រះសាលាដំបូងសូមជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទដែលអង្គជំនុំជម្រះ គ្រោងនឹងស្តាប់សក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ចុងក្រោយ ដែលនៅសេសសល់ និងសវនាការផ្សេងៗដែលនឹងត្រូវធ្វើមុនពេលបញ្ចប់កិច្ចពិភាក្សាដេញដោល លើភស្តុតាងលើសំណុំរឿង ០០២/០១។

២ នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចស្តាពររបស់ខ្លួនស្តីពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ដោយលើកឡើងអំពីមូលដ្ឋាននៃការជ្រើសរើសបុគ្គលនានាដើម្បីស្តាប់ចម្លើយនៅពេលសវនាការ ព្រមជាមួយសេចក្តីសម្រេចមួយចំនួនតូចផ្សេងទៀតដែលនៅសេសសល់ ដែលស្ថិតនៅក្រោមការពិចារណាចំពោះមុខអង្គជំនុំជម្រះ។ នៅប៉ុន្មានថ្ងៃខាងមុខនេះ ឧបសម្ព័ន្ធមួយដែលភ្ជាប់សំណើទាំង

អស់ដែលត្រូវបានដាក់ក្នុងអំឡុងពេលសវនាការលើសំណុំរឿង ០០២/០១ និងសេចក្តីសម្រេចតបទៅនឹងសំណើទាំងនោះនឹងត្រូវបញ្ជូនទៅឱ្យភាគី។ ឧបសម្ព័ន្ធនេះនឹងដាក់បញ្ចូលនូវកាលបរិច្ឆេទតាមការរំពឹងទុកនៃការចេញសេចក្តីសម្រេចចុងក្រោយទៅនឹងសំណើដែលនៅសេសសល់ក្រោមការពិចារណាចំពោះមុខអង្គជំនុំជម្រះ។ តាមសំណើរបស់ភាគី និងតាមការរំពឹងទុកកន្លងមករបស់អង្គជំនុំជម្រះ សេចក្តីសម្រេចទាំងនោះក៏កំណត់កាលបរិច្ឆេទកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយមួយនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ នាវេលាម៉ោង ០៩ ព្រឹក នៅឯសាលសវនាការធំនៃ អ.វ.ត.ក។

៣ នៅមុនកិច្ចប្រជុំរៀបចំសវនាការនេះ ឧបសម្ព័ន្ធទាំងអស់នៃសេចក្តីសម្រេចពាក់ព័ន្ធនឹងសាក្សី ក៏នឹងត្រូវប្រគល់ជូនភាគីផងដែរ។ ឧបសម្ព័ន្ធទាំងនេះរួមមានបញ្ជីចំនួន ០៣ ដែលបញ្ជីទីមួយគឺជាបញ្ជីឈ្មោះបុគ្គលទាំងអស់ដែលត្រូវបានស្តាប់ចម្លើយរួចហើយ ឬបុគ្គលដែលនឹងត្រូវកោះហៅមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១។ បញ្ជីទីពីររាយនាមបុគ្គលដែលភាគីបានស្នើសុំកោះហៅនៅក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែពុំទាន់ត្រូវបានស្តាប់សក្ខីកម្មនៅពេលសវនាការ ហើយដែលត្រូវបានបដិសេធ ឬពន្យារពេលសម្រាប់សវនាការនាពេលខាងមុខ។ បញ្ជីទីបីជាបញ្ជីឈ្មោះបុគ្គលទាំងអស់ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីបឋមរបស់ភាគីនៃសំណុំរឿង ០០២ ដោយអនុលោមតាមវិធាន៨០ ប៉ុន្តែបុគ្គលទាំងនោះពុំទាន់ត្រូវបានភាគីណាមួយស្នើសុំស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ នៅឡើយ។ សេចក្តីសម្រេចពាក់ព័ន្ធនឹងបុគ្គលទាំងឡាយនៅក្នុងបញ្ជីចុងក្រោយនេះត្រូវបានពន្យារពេលសម្រាប់សវនាការនៅថ្ងៃខាងមុខ។ ភាគីនឹងត្រូវបានផ្តល់ឱកាសដើម្បីលើកអំពីបញ្ហាថ្មីពាក់ព័ន្ធនឹងឧបសម្ព័ន្ធទាំងនេះ និងអំពីបុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីនោះនៅឯកិច្ចប្រជុំរៀបចំសវនាការ។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាបញ្ហាដែលត្រូវបានលើកឡើងនៅក្នុងអនុស្សរណៈនេះនឹងជារបៀបវារៈសម្រាប់កិច្ចប្រជុំរៀបចំសវនាការ បើទោះបីជាភាគីអាចលើកបញ្ហាពាក់ព័ន្ធផ្សេងៗទៀតក៏ដោយ។

<u>សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញចុងក្រោយ ដែលត្រូវផ្តល់សក្ខីកម្មនៅពេលសវនាការ</u>

៤ ក្រៅពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងឡាយដែលត្រូវបានកំណត់កាលបរិច្ឆេទដើម្បីផ្តល់សក្ខីកម្ម អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់បុគ្គលខាងក្រោមនេះ ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E236/5, E236/1/4/3 និង E266/3)។ អង្គជំនុំជម្រះបានទទួលដំណឹងថាអ្នកជំនាញឈ្មោះ Stephen HEDER ពុំបានទទួលយកការតែង

តាំងជាអ្នកជំនាញនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងឡើយ(ឯកសារ E202/82/1)។ ហេតុនេះ នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះសាលាដំបូងនឹងកោះហៅគាត់ក្នុងនាមជាសាក្សីលើអង្គហេតុទាក់ទងនឹងឯកសារជាច្រើននៅក្នុងសំណុំរឿងដែលគាត់បានសរសេរ។

៥ អនុលោមតាមសំណើរបស់សហព្រះរាជអាជ្ញា (E286) នាពេលបច្ចុប្បន្ននេះអង្គជំនុំជម្រះកំពុងពិនិត្យមើលអំពីលទ្ធភាពនៃការកោះហៅដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-186 ឡើងវិញ ហើយនឹងជូនដំណឹងទៅភាគីឆាប់ៗតាមដែលអាចធ្វើទៅបាន។

៦ ជនជាប់ចោទកាលពីពេលថ្មីៗបានបញ្ជាក់អះអាងថា ពួកគាត់នឹងឆ្លើយរាល់សំណួរនានារបស់អង្គជំនុំជម្រះ និងភាគីដោយអនុលោមតាមវិធាន៩០ នៃវិធានផ្ទៃក្នុង។ សកម្មភាពនេះនឹងចាប់ផ្តើមក្រោយសវនាការដូចដែលត្រូវបានកំណត់កាលបរិច្ឆេទខាងក្រោមនេះ។ ភាគីត្រូវបានស្នើសុំឱ្យជូនដំណឹងមកអង្គជំនុំជម្រះឱ្យបានត្រឹមម៉ោង ០៩ ព្រឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣ អំពីពេលវេលាដែលខ្លួនត្រូវការសម្រាប់គោលបំណងនេះ។ ជនជាប់ចោទក៏អាចធ្វើសេចក្ដីសន្និដ្ឋានផងដែរនៅក្នុងអំឡុងពេលនៃការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល ដោយអនុលោមតាមវិធាន ៩៤(១)(ឃ) នៃវិធានផ្ទៃក្នុង។

| | |
|---|---|
| ថ្ងៃទី ០៤,០៥,០៦,០៧ ខែ មិថុនា (ថ្ងៃទី ០៣ ខែ មិថុនា – ថ្ងៃឈប់សម្រាក អ.វ.ត.ក)<br><br>ក.ស.ព = សហព្រះរាជអាជ្ញា<br>Δ = ក្រុមមេធាវីការពារក្ដី<br>ដ.ប.រ = ដើមបណ្ដឹងរដ្ឋប្បវេណី | **ថ្ងៃទី ០៤ ខែ មិថុនា**<br>ដើមបណ្ដឹងរដ្ឋប្បវេណី – សវនាការស្ដីពីផលប៉ះពាល់មកលើជនរងគ្រោះ (បន្ត)<br><br>**ថ្ងៃទី ០៥, ០៦ ខែ មិថុនា (សវនាការពេលព្រឹក – ប្រព័ន្ធសោតទស្សន៍)**<br>សាក្សីដែលមានរហស្សនាម TCW-624 (ក.ស.ព/ដ.ប.រ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)<br><br>**ថ្ងៃទី ០៥ ខែ មិថុនា (សវនាការពេលរសៀល)**<br>អ្នកជំនាញដែលមានរហស្សនាម TCE-12 (ដ.ប.រ ១០៥ នាទី; ក.ស.ព/Δ ៤៥ នាទី)<br><br>**ថ្ងៃទី ០៦ ខែ មិថុនា (សវនាការពេលរសៀល) និងថ្ងៃទី ០៧ ខែ មិថុនា** |

00916367

E288

| | |
|---|---|
| | សាក្សីដែលមានរហស្សនាម TCW-742 (Δ ៧៥ នាទី; ក.ស.ព/ជ.ប.រ ៧៥ នាទី)<br>សាក្សីដែលមានរហស្សនាម TCW-673 (Δ ៧៥ នាទី; ក.ស.ព/ជ.ប.រ ៧៥ នាទី)<br>សាក្សីដែលមានរហស្សនាម TCW-665 (Δ ៧៥ នាទី; ក.ស.ព/ជ.ប.រ ៧៥ នាទី) |
| ថ្ងៃទី ១០,១១,១២,១៣ ខែ មិថុនា | សាក្សីដែលមានរហស្សនាម TCW-648 (ក.ស.ព/ជ.ប.រ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)<br>[redacted] (ក.ស.ព/ជ.ប.រ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)<br>សាក្សីដែលមានរហស្សនាម TCW-384 (ក.ស.ព/ជ.ប.រ កន្លះថ្ងៃ; Δ កន្លះថ្ងៃ)សវនាការដេញដោលលើឯកសារ |

## សវនាការលើភស្តុតាងលើកចុងក្រោយ

៧ សហព្រះរាជអាជ្ញាស្នើសុំឱកាសដើម្បីបង្ហាញឯកសារគន្លឹះសំខាន់ៗ ពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា និងសហឧក្រិដ្ឋកម្មរួម (ឯកសារ E273, កថាខណ្ឌ ១១)។ អង្គជំនុំជម្រះកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការចុងក្រោយលើការបង្ហាញឯកសារគន្លឹះសំខាន់ៗដែលនឹងចាប់ផ្តើមធ្វើយ៉ាងឆាប់បំផុត ក្នុងអំឡុងសប្តាហ៍ដែលចាប់ផ្តើមពីថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១៣ តទៅ។ អង្គជំនុំជម្រះកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាចំនួនបីថ្ងៃដើម្បីបង្ហាញឯកសារគន្លឹះទាំងនោះ អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីអំពីការបែងចែកពេលវេលាជាក់លាក់នៅពេលដ៏ខ្លីខាងមុខនេះ។ នាពេលឆាប់ៗនេះដែរ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដែលមានសំអាងហេតុស្តីពីភាពអាចទទួលយកបាននៃចម្លើយជាលាយលក្ខណ៍អក្សរដោយយោងទៅលើសារណាជាច្រើនដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ សវនាការបន្ថែមលើបញ្ហានេះពុំចាំបាច់ឡើយ។

## សារណានិងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល

៨ កន្លងមកអង្គជំនុំជម្រះសាលាដំបូង បានជូនដំណឹងទៅភាគីថាគ្រប់ភាគីទាំងអស់នឹងមានពេលវេលាចំនួន៣០ថ្ងៃ ដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល បន្ទាប់ពីថ្ងៃចុងក្រោយនៃសវនាការលើភស្តុតាងក្នុងសំណុំរឿង០០២/០១ ដែលនឹងត្រូវប្រកាសដោយប្រធានអង្គជំនុំជម្រះ (E163/

5/4)។ ចំនួនទំព័រកំណត់គឺដូចដែលបានជូនដំណឹងនៅក្នុងឯកសារ E163/5/4។

៩ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញអំពីកាលបរិច្ឆេទនេះ និងបង្គាប់ឱ្យដាក់សារណាស្ថាពរក្នុងអំឡុងពេល ០៦សប្តាហ៍ គិតចាប់ពីថ្ងៃចុងក្រោយនៃសវនាការ (ឯកសារ E273, កថាខណ្ឌ ១២)។ ភាគី បានទទួលការជូនដំណឹងអំពីកាលបរិច្ឆេទនេះចាប់តាំងពីខែ វិច្ឆិកា ឆ្នាំ ២០១២ ហើយពួកគាត់បានប្រើប្រាស់ឱកាសនេះកាលពីពេលមុនដើម្បីដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលស្តីពីច្បាប់ជាធរមាន។ គោលបំណងនៃការកំណត់កាលបរិច្ឆេទរបស់ អង្គជំនុំជម្រះគឺដើម្បីធានាបាននូវការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងដើម្បីសម្រួលដល់ការត្រៀមរៀបចំបានទាន់ពេលវេលានៃសាលក្រមសំណុំរឿង ០០២/០១។ ដោយទទួលស្គាល់ថានេះជាការទាមទារចំពោះភាគី អង្គជំនុំជម្រះអនុញ្ញាតជាពិសេសឱ្យភាគីដាក់ជាដំណាក់កាលដំបូងនូវសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលមួយភាសាផ្លូវការ អ.វ.ត.ក ។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធសំណើរបស់សហព្រះរាជអាជ្ញា។

១០ដើម្បីធានាបានការបញ្ចប់ទាន់ពេលវេលានៃសាលក្រមសម្រាប់សំណុំរឿង០០២/០១ និង អនុលោមតាមវិធាន ១០៤(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងពុំពន្យារពេលការបញ្ចប់កិច្ចដំណើរការនីតិវិធីដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការជាថ្មីឡើយ (ឯកសារ E284) លើកលែងតែមានការបង្គាប់ដូច្នេះពីសំណាក់អង្គជំនុំជម្រះតុលាការកំពូល។ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនឹងធ្វើឡើង ៣០ ថ្ងៃ ក្រោយថ្ងៃដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល (ឯកសារ E163/5/4)។ សហព្រះរាជអាជ្ញាស្នើសុំពេលវេលាសរុបចំនួន ០៥ ថ្ងៃសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល (ឯកសារ E273.1)។ អង្គជំនុំជម្រះពិចារណាឃើញថាសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល គួរគប្បីជាសេចក្តីសង្ខេបអំពីសេចក្តីសន្និដ្ឋានរបស់ខ្លួន ឬការបដិសេធសេចក្តីសន្និដ្ឋានរបស់ភាគីដទៃទៀត ដោយហេតុថាភាគីមានឱកាសដើម្បីលើកអំពីផ្នែកនៃទឡ្ហីករណ៍របស់ពួកគាត់នៅក្នុងសារណាជាលាយលក្ខណ៍អក្សរ។ហេតុដូច្នេះ អង្គជំនុំជម្រះកំណត់ពេលវេលាសម្រាប់ភាគីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលដូចខាងក្រោមនេះ៖

-ការិយាល័យសហព្រះរាជអាជ្ញា ០៣ ថ្ងៃ

-សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ០១ ថ្ងៃ

-មេធាវីការពារក្តីលោក នួន ជា ០២ ថ្ងៃ

-មេធាវីការពារក្តីលោក ខៀវ សំផន ០២ ថ្ងៃ

ដើម្បីតម្លាភាព អង្គជំនុំជម្រះនឹងជូនដំណឹងទៅភាគីនាពេលក្រោយទៀតអំពីកាលបរិច្ឆេទជាក់លាក់នៃពេលវេលាផុតកំណត់នៃការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល ព្រមទាំងកាលបរិច្ឆេទដែលត្រូវបានកំណត់សម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលផងដែរ។